មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ៨៩ សសរ

### ស្តីពីការបង្កើត

### គណៈកម្មការជាតិពិគ្រោះផ្តល់យោបល់ និង

### ដោះស្រាយបាតុភាពលើការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល

- បានឃើញសេចក្ដីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ ស្ដីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យ ក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល
- យោងសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

សំរេច

**[ប្រការ] ១ :** បង្កើតគណៈកម្មការជាតិអន្តរក្រសួងមួយ ដើម្បីពិភាក្សាផ្ដល់យោបល់ និងដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្ដម | ម៉ុក ម៉ារ៉េត | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្ដម | គៀង វ៉ាង | រដ្ឋលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឯកឧត្ដម | ច័ន្ទ គុងអ៊ីច | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- ឯកឧត្ដម | លី ធុច | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥- ឯ.ឧ.ឧត្ដមសេនីយ៍ឯក | ម៉ុល សារឿន | អគ្គមេបញ្ជាការរងនៃបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦- ឯ.ឧ.ឧត្ដមសេនីយ៍ឯក | ហុក ឡុងឌី | អគ្គនាយកនគរបាលជាតិ | សមាជិក |
| ៧- ឯ.ឧ.ឧត្ដមសេនីយ៍ឯក | សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៨- ឯកឧត្ដម | ស៊ិន សារុន | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- ព្រះអង្គម្ចាស់ | ស៊ីសុវត្ថិ ជីវណ្ណាមុន្នី | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១០- ឯកឧត្ដម | អ៊ុំ ម៉ុនឡឿន | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១១- ឯកឧត្ដម | កែវ ខេមរា | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ១២- ឯកឧត្ដម | អភិបាលខេត្ត-ក្រុង ដែលពាក់ព័ន្ធ | | សមាជិក |

**ប្រការ ២ :** គណៈកម្មការជាតិអន្តរក្រសួងនេះ មានភារកិច្ច និងបេសកកម្មដូចតទៅ :

- ចូលរួមពិភាក្សាផ្ដល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ចូលរួមពិភាក្សាផ្ដល់យោបល់ លើការងារអភិរក្ស និង អភិវឌ្ឍន៍ត ការពារធម្មជាតិ
- លើកវិធានការទប់ស្កាត់ និង ដោះស្រាយជាបន្ទាន់ នូវរាល់សកម្មភាពអនាធិបតេយ្យ ដែលកើតឡើងក្នុងតំបន់ការពារធម្មជាតិ

- ចូលរួមវាយតម្លៃ និង ពិភាក្សាផ្តល់យោបល់ លើរាល់ការងារពាក់ព័ន្ធដល់ការកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិ

ប្រការ ៣ : គណៈកម្មការជាតិអន្តរក្រសួងនេះ ត្រូវបង្កើតអនុគណៈកម្មការចំរុះមួយនៅតាមបណ្តាខេត្ត-ក្រុងពាក់ព័ន្ធដែលមានអភិបាលខេត្តរង ០១រូប ជាប្រធាន ដើម្បីជាជំនួយការសំរាប់បំពេញភារកិច្ចនៅតាមបណ្តាខេត្ត-ក្រុង ដែលមានតំបន់ការពារធម្មជាតិ ។

ប្រការ ៤ : គណៈកម្មការជាតិអន្តរក្រសួងនេះ មានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីស្នាក់ការអចិន្ត្រៃយ៍នៅទីស្តីការក្រសួងបរិស្ថាន និង ប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

ប្រការ ៥ : សមាជិកគណៈកម្មការជាតិតំណាងឲ្យក្រសួង-ស្ថាប័ន ខេត្ត-ក្រុងនានា និងអនុគណៈកម្មការខេត្ត-ក្រុង ត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ២ ខាងលើនិងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការជាតិអន្តរក្រសួង ហើយរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

មាត្រា ៦.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង អនុគណៈកម្មការ និងសមាគមភាពដែលមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★